ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ

## កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផល ស្ដីពី ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ (២០១៩-២០២៣) លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ថ្ងៃសុក្រ ដប់បីកើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំ ត្រូវនឹងថ្ងៃទីដប់ប្រាំពីរ ខែធ្នូ ឆ្នាំពីរពាន់ម្ភៃមួយ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក មានបើកកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីពិនិត្យលទ្ធផល ស្ដីពី «**ការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិ ០៥ឆ្នាំ (២០១៩-២០២៣) លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**» ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដោយមានការអញ្ជើញចូលរួមពី **លោកស្រី រ៉ូប៊ីន ម៉ូនី** ទីប្រឹក្សាបច្ចេកទេសអង្គការ វីនរ៉ក់អន្តរជាតិ **លោក ម៉ាក ថាយ៍ល័រ** (Mark Taylor) ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គលេខាធិការ អគ្គនាយករង អគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានលេខាធិការដ្ឋាន និងមន្ត្រីបច្ចេកទេសតំណាងក្រសួង ស្ថាប័ន ព្រមទាំងតំណាងអង្គការដៃគូមួយចំនួនទៀត សរុបប្រមាណចំនួន ១០០រូប ។

ជាកិច្ចចាប់ផ្ដើម នៃកិច្ចប្រជុំ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍សំណេះសំណាល ស្វាគមន៍ និងបើកកិច្ចប្រជុំ ដោយបានផ្ដាំផ្ញើថា កិច្ចប្រជុំនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះគឺជាការពិនិត្យមើលនូវលទ្ធផលការអនុវត្តសកម្មភាពការងារកន្លងមកអស់រយៈពេល៣ឆ្នាំ នៃផែនការយុទ្ធសាស្ត្រជាតិរយៈពេល០៥ឆ្នាំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លុះបញ្ចាំងពីចំណុចដែលបានអនុវត្តល្អ និងចំណុចដែលត្រូវកែលម្អ សម្រាប់ពាក់កណ្ដាលអាណត្តិបន្តទៀត។ ដូច្នេះរាល់មតិយោបល់របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមានក្នុងកិច្ចប្រជុំនេះ គឺជាធាតុចូលសម្រាប់ការកែសម្រួល ផែនការយុទ្ធសាស្ត្រ ក៏ដូចជាផែនការសកម្មភាពយុទ្ធសាស្ត្រ ដើម្បីជានាំឲ្យសម្រេចបានតាមការគ្រោងទុក ។

**លោកស្រី** Robin Mauney ទីប្រឹក្សាបច្ចេកទេសអង្គការវីនរ៉ក់អន្តរជាតិ បានធ្វើបទបង្ហាញស្ដីពីលទ្ធផលនៃការពិនិត្រឡើងវិញ ពាក់កណ្ដាលអាណត្តិនៃផែនការយុទ្ធសាស្ត្រជាតិ០៥ឆ្នាំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានខ្លឹមសារសំខាន់ៗតាមរយៈការបង្ហាញ Slide ជូនអង្គប្រជុំ ។

**លោក ផុន ពុទ្ធបូរី** តំណាងក្រសួងកិច្ចការនារី សំណូមពរបន្ថែមចំណុចដែលបានបញ្ជាក់ពីសម្រង់សម្ដីមន្ត្រីនៃ ក្រសួងកិច្ចការនារីចូលទៅក្នុងរបាយការណ៍។ ចំណុចមួយទៀត យើងពុំទាន់មានច្បាប់ពរពោះជំនួសនៅ

ឡើយទេ ប៉ុន្តែយើងមានច្បាប់ពាក់ព័ន្ធផ្សេងៗ។ របាយការណ៍វាយតម្លៃនេះ បើពិនិត្យមើលទៅឃើញថាហាក់បីដូចជាពឹងផ្អែកខ្លាំងទៅលើរបាយការណ៍ បីខែ ៦ខែ និង៩ខែ ក្នុងឆ្នាំ២០២១ ជាជាងការធ្វើការពិនិត្យក្នុងរយៈពេលបីឆ្នាំ។ គួរមានជាអនុសាសន៍ សម្រាប់តម្រង់ទិស សម្រាប់ពាក់កណ្តាលអាណត្តិទៅខាងមុខ ដោយកំណត់ជាអាទិភាព ។

**លោកស្រី** Robin Mauney បានទទួលយកក្នុងការដាក់បញ្ចូលឈ្មោះក្រសួងកិច្ចការនារី ទៅក្នុងរបាយការណ៍។ ឆ្លើយតបទៅនឹងការពឹងផ្អែកលើរបាយការណ៍ លោកស្រីក៏បានទទួលស្គាល់ថា គឺពិតជាបានផ្អែកទៅលើរបាយការណ៍ឆ្នាំ២០២១ពិតមែន ប៉ុន្តែយើងពិនិត្យឃើញថា នៅក្នុងរបាយការណ៍ឆ្នាំ២០២១ គឺបានបញ្ចូលជាច្រើននូវ លទ្ធផលដែលបានពីឆ្នាំកន្លងៗមក ដោយឡែកនៅក្នុងឆ្នាំ២០១៩-២០២០ យើងពុំឃើញមានរបាយការណ៍ជាក់លាក់ណាមួយពីក្រសួងស្ថាប័នពាក់ព័ន្ធ ដែលអាចពឹងពាក់បានឡើយ ។

**លោកជំទាវ** អនុប្រធានអចិន្ត្រៃយ៍ បានគូសបញ្ជាក់ថា លោកជំទាវ ពិតជាទទួលស្គាល់ថា គឺពិតជាមានការខ្វះចន្លោះពាក់ព័ន្ធការធ្វើរបាយការណ៍ ជាក់ស្តែងសម្រាប់របាយការណ៍ ដែលទទួលបានពីក្រសួងស្ថាប័នពាក់ព័ន្ធក្នុងឆ្នាំកន្លងមក គឺលេខាធិការដ្ឋានមានការលំបាកយ៉ាងខ្លាំងក្នុងការបូកសរុបលទ្ធផល ព្រោះទិន្នន័យពុំឆ្លុះបញ្ចាំងគ្នា និងមិនស៊ីសង្វាក់គ្នា ជាហេតុធ្វើឲ្យយើងពុំអាចយកជាយោងបាន។

**លោក ហាន ឧសភា** បានសម្តែងនូវការកោតសរសើរ និងបានចូលរួមថា គួររំលេចអំពីការចូលរួម និងធនធានមនុស្សដែលកម្ពុជាមាន ។

**លោកស្រី** Robin Mauney ទទួលស្គាល់ថា ចំណុចនេះគឺពិតជាមានការរសើប។ យើងត្រូវធ្វើការតស៊ូមតិជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយយើងនឹងរំលេចនៅក្នុងអនុសាសន៍។

លោកជំទាវ ប្រធានអង្គប្រជុំ បានបន្ថែមថា ជាក់ស្តែងប្រសិនបើប្រមូលធនធានទាំងអស់គិតជាទឹកប្រាក់ គឺពុំអាចប៉ាន់ប្រមាណបានទេ។ ព្រោះកន្លងមក សកម្មភាពដែលយើងបានអនុវត្ត គឺប្រើប្រាស់ធនធានដែលមានស្រាប់ តាមរយៈការព្រង្រឹងយន្តការដែលមានស្រាប់ ដែលឆ្ពោះទៅរកគោលដៅរួម ដោយពុំមានការប្រកួតប្រជែង ឬបែងចែករវាងថវិការដ្ឋ និងថវិកាអង្គការដៃគូ នោះឡើយ។ ឧទាហរណ៍ ប្រមុខដឹកនាំនៃក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន បានប្តេជ្ញាចិត្តក្នុងការពង្រឹងយុទ្ធសាស្ត្ររបស់ខ្លួន ដើម្បីចូលរួមចំណែកក្នុងការលុបបំបាត់ អំពើជួញដូរមនុស្ស ទាំងនេះគឺសុទ្ធតែជាការចូលរួមចំណែក ប៉ុន្តែពុំអាចប៉ាន់ប្រមាណនូវតម្លៃជាមុនបានទេ។

**ឯកឧត្តម ហោ សារុន** បានមានប្រសាសន៍ចូលរួមថា ក្រសួងស្ថាប័នពាក់ព័ន្ធ គួរមានត្រៀមទុកនូវកញ្ចប់ថវិកា សម្រាប់ការងារប្រយុទ្ធប្រឆាំងជួញដូរមនុស្ស នៅក្នុងផែនការថវិកាជាតិរបស់ខ្លួន ឬក្រសួងសេដ្ឋកិច្ចគួរមានជាកញ្ចប់ថវិកាពិសេសសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយ គ.ជ.ប.ជ ជាអ្នកទំលាក់កញ្ចប់ថវិកានេះទៅឲ្យក្រសួងស្ថាប័នដែលជាសមាជិកជាអ្នកអនុវត្ត។ សម្រាប់ក្រសួងទេសចរណ៍ យើងបានរៀបចំជាផែនទីអភិវឌ្ឍរបស់ខ្លួនជាបីដំណាក់កាល និងបានដាក់ចេញនូវវិធានសុវត្ថិភាពទេសចរណ៍ សម្រាប់ភ្ញៀវទេសចរណ៍ នៅតាមគោលដៅទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**លោកជំទាវ** ប្រធានអង្គប្រជុំ បានសម្តែងនូវការកោតសរសើរចំពោះ ឯកឧត្តម ក្រសួងទេសចរណ៍ ដែលបានខិតខំប្រឹងប្រែង ឆ្លើយតបទៅនឹងអនុសាសន៍ក្នុងការស្នើឲ្យគ.ជ.ប.ជ ជាអ្នកបែងចែកកញ្ចប់ថវិកា គឺជាការ

លំបាក ព្រោះកញ្ចប់ថវិកានឹងធំធេងពេក ហើយមានចំណុចមួយចំនួនដែលយើងពិបាកនឹងបាន់ស្មានថវិកាបាន ឧទាហរណ៍ដូចជា សកម្មភាពពង្រឹងសមត្ថភាព លើកកម្ពស់ការយល់ដឹង។

**ឯកឧត្តម ហ៊ូ ឧុឌ្ឋី** មានប្រសាសន៍ស្នើឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ ពាក់ព័ន្ធទៅនឹងអនុសាសន៍ ឧទាហរណ៍ថា ជំរុញការអប់រំណែនាំតម្រង់ទិស តើចង់ផ្តោតទៅលើអ្វីជាសំខាន់? ព្រោះថាបើគ្រាន់តែបង្ហាញពីចំណុចរកឃើញ ប៉ុន្តែមិនបានផ្តល់ជាអនុសាសន៍ដើម្បីកែលម្អ យើងគឺពិតជាលំបាកក្នុងការអនុវត្តនៅពេលអនាគត

**លោក ប៉ាក់ យូលាង** ស្នើសុំឲ្យរំលេចនូវចំនួនករណីដែលបានបង្ក្រាប ឲ្យបានស៊ីគ្នាជាមួយនឹងទិន្នន័យក្នុងការផ្តន្ទាទោស ។ បញ្ជាក់ថា គ្រាន់តែចង់ឲ្យរំលេចនូវទិន្នន័យនៃការបង្ក្រាបក្នុងឆ្នាំនីមួយៗ ប៉ុន្តែពុំចាំបាច់ថាឲ្យត្រូវគ្នាជាមួយនឹងចំនួនករណីកាត់ទោសទេ។

**លោកស្រី ស៊ុន សុខាលីដា** ក្រសួងយុត្តិធម៌ ចំពោះការចង់ឲ្យរំលេចចំនួនករណីដែលបានបង្ក្រាបកាត់ទោស គឺលំបាកព្រោះមិនមែនមានន័យថា ការបង្ក្រាបនៅក្នុងឆ្នាំបានចំនួន១០០ករណី នឹងទទួលបានការកាត់ទោសក្នុងឆ្នាំដដែលនោះឡើយ ព្រោះដំណាក់កាលនៃការកាត់ទោសគឺមានបី។

**លោក ថា សាវ៉ាឌុទ្ធ** UNDP កោតសរសើរ ប៉ុន្តែលទ្ធផលដែលបានបង្ហាញហាក់មិនមានភាពឆ្លើយតបគ្នា ឧទារណ៍ របាយការណ៍បានលើកឡើងថា រចនាសម្ព័ន្ធមានភាពច្បាស់លាស់ ប៉ុន្តែនៅក្នុងអនុសាសន៍ថា ត្រូវកែលម្អរចនាសម្ព័ន្ធ តើមានន័យយ៉ាងណា?

**លោកស្រី រ៉ូប៊ីន ម៉ូនី** បញ្ជាក់ថា រចនាសម្ព័ន្ធល្អតែក្នុងឯកសារ ប៉ុន្តែការអនុវត្តជាក់ស្តែងគឺនៅមានភាពខ្វះចន្លោះ ដូចជាពុំសូវដឹងពីការទទួលខុសត្រូវរបស់ខ្លួនក្នុងនាម គ.ជ.ប.ជ។ ដូចជានៅក្នុងរយៈពេលជាងមួយឆ្នាំចុងក្រោយនេះ រវាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គឺសុទ្ធតែធ្វើការងារក្នុងការជួយពលករវិលត្រឡប់ ដូច្នេះគួរធ្វើការបែងចែកការងារគ្នាឲ្យបានច្បាស់ថាអ្នកណាទទួលខុសត្រូវអ្វី? កម្រិតណា?

**លោកជំទាវ** ប្រធានអង្គប្រជុំ គាំទ្រហើយអ្វីដែលចង់បញ្ជាក់បន្ថែមគឺចង់ឲ្យក្រសួងស្ថាប័នពាក់ព័ន្ធយល់ថា រាល់ការងារទាំងឡាយ គឺគួរមានការចែករំលែកព័ត៌មានគ្នាជាមុន ជៀសវាងការជាន់សកម្មភាពគ្នា។

**លោក សំលៀង សិលា** ចូលរួមមតិចូលរួមក្នុងកិច្ចប្រជុំភ្ជាប់ជាមួយលើកឡើងរបស់ **លោកឧត្តមសេនីយ៍ទោ ប៉ាក់ យូលាង** ពាក់ព័ន្ធស្ថិតិបង្ក្រាប និងផ្តន្ទាទោស និងសូមឯកភាពការលើកឡើងរបស់ **លោកឧត្តមសេនីយ៍ទោ** ទាក់ទងការបង្ហាញតួលេខ នៃការកាត់ទោសប្រចាំឆ្នាំ តើមានការកើនឡើង ឬថយចុះ។ លោក បានសំណូមពរ ប្រសិនបើអាចសូមឲ្យមានការបង្ហាញស្ថិតិ ទិន្នន័យករណីបណ្តឹងពាក់ព័ន្ធអំពើជួញដូរមនុស្ស ដែលបានដាក់ទៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឬ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ។

តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានមតិស្នើសុំបំពេញបន្ថែមសកម្មភាពការងារមួយចំនួន របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងបញ្ជូនទិន្នន័យមកបន្ទាប់ពីកិច្ចប្រជុំចប់ ។

តំណាងអង្គការ ILO ស្នើដាក់បញ្ចូលសកម្មភាពរបស់វិស័យឯកជន ពាក់ព័ន្ធផ្នែកបច្ចេកទេស ក៏ដូចជាធនធានលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**លោក កេខ ម៉ុនឈឿត** តំណាងអង្គការ ERIKS មានមតិលើកឡើងពាក់ព័ន្ធយុទ្ធសាស្ត្រទី២ ពាក្យថាការជួញដូរមនុស្សមានសកម្មភាពបែបណា? មានរូបភាពបែបណា? គួរធ្វើការបញ្ជាក់ដល់ថ្នាក់ភូមិ/ឃុំ ក៏ដូចជាសមត្ថកិច្ចដែលជាអ្នកអនុវត្តច្បាប់ ដើម្បីឲ្យមានការយល់ឃើញដូចគ្នា ។

**លោក ឌី នឿត** តំណាងអង្គការចាប់ដៃ មានមតិសំណូមពរ គ.ជ.ប.ជ ផលិតឯកសារផ្សព្វផ្សាយរួមមួយសម្រាប់ក្រសួងស្ថាប័ន ក៏ដូចជាអង្គការដៃគូពាក់ព័ន្ធ អាចយកទៅប្រើប្រាស់រួមតែមួយ ចៀសវាងការផលិតរៀងៗខ្លួនធ្វើឲ្យមានភាពច្របូកច្របល់ដល់ប្រជាជននៅមូលដ្ឋាន។

**លោកជំទាវ** ប្រធានអង្គប្រជុំ អ្វីដែលបានធ្វើកន្លងមកគឺមិនមានន័យថា យើងធ្វើមិនត្រឹមត្រូវនោះទេ ព្រោះកាលៈទេសៈនោះ គ្រប់គ្នាត្រូវចាប់ផ្តើមធ្វើ ដែលពុំអាចនៅរង់ចាំបាន ហើយធនធានទៀតសោត ក៏ជាធនធានដែលមានស្រាប់ក្នុងស្ថាប័ននីមួយៗ ម្យ៉ាងក្រសួងស្ថាប័ននិងអង្គការដៃគូមួយចំនួនក៏ចង់រំលេចនូវស្នាដៃរបស់ខ្លួនផងដែរ ទើបហាក់បីដូចជាពុំមានលក្ខណៈរួម ។ **លោកជំទាវ** សំណូមពរឲ្យក្រសួងស្ថាប័នពាក់ព័ន្ធ ធ្វើយ៉ាងណាឲ្យយល់ពីគ្នាទៅវិញទៅមកជាមុនសិន មុននឹងយកទៅនិយាយជាមួយប្រជាជននៅមូលដ្ឋាន ជៀសវាងការយល់ខុស។

**លោក កុសល់** តមណាងអង្គការ HAGA មានមតិពាក់ព័ន្ធនឹងទីភ្នាក់ងារមុខរបរ ព្រោះបច្ចុប្បន្នការទប់ស្កាត់របស់យើងនៅមានកម្រិតនៅឡើយ តើយើងត្រូវប្រឹក្សាយោបល់ជាមួយពួកគាត់ដែរទេ ចំពោះអ្នកដែលរៀបចាកចេញទៅ ឬអ្នកត្រឡប់មកវិញ ។

**លោក កុយ ចំរើន** តំណាងអង្គការ CARE ចូលរួមថា ពលករដែលបានវិលត្រឡប់មកវិញក្នុងអំឡុងកូវីដភាគច្រើនចង់ត្រឡប់ទៅវិញ ព្រោះពួកគេពុំអាចរកបានការងារសមស្របនៅក្នុងប្រទេសបាន។

**លោកជំទាវ** ប្រធានអង្គប្រជុំ ចង់រៀបចំសិក្ខាសាលាជាមួយពលករដែលបានវិលត្រឡប់ ដើម្បីសិក្សាពីសេចក្តីត្រូវការរបស់ពួកគាត់ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្របន្ទាប់។

**លោក ម៉ាក ថៃល័រ** មានសេចក្តីសោមនស្សរីករាយ ដោយបានឃើញការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធយ៉ាងច្រើន និងបានឃើញរបាយការណ៍លទ្ធផលនៃការវាយតម្លៃ។ ចូលរួមពិនិត្យឃើញតម្រូវការ ឲ្យមានការចែករំលែកព័ត៌មានក្នុងការអនុវត្តការងារ ។ ការស្នើឲ្យមានមូលនិធិជំនួយដល់ជនរងគ្រោះនៅដំណាក់កាលតុលាការ។ រៀបចំឲ្យមានក្រុមការងារសម្របសម្រួល ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ ដើម្បីឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សអាចប្រព្រឹត្តទៅបានតាមផែនការ សម្រាប់រយៈពេលពីរឆ្នាំបន្ទាប់ទៀត។ ពិនិត្យឃើញមានកិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាក្នុងដំណាក់កាលកូវីដ ដែលសកម្មភាពទាំងនេះពុំត្រូវបានគ្រោងទុក ដែលជាសញ្ញាមួយល្អយ៉ាងខ្លាំង។ USAID តាមរយៈ WINROCK នឹងត្រៀមខ្លួនសម្រាប់ការចូលរួមគាំទ្រសកម្មភាពរបស់ គ.ជ.ប.ជ ជានិច្ច ។

**លោកជំទាវ** ប្រធានអង្គប្រជុំបានមានប្រសាសន៍បូកសរុបកិច្ចប្រជុំដូចខាងក្រោម៖ ជារួមលទ្ធផលគឺអាចទទួលយកបាន ដោយមានការរកឃើញចំណុចល្អ និងមានការផ្តល់នូវអនុសាសន៍សម្រាប់ការកែលម្អ ចំពោះក្រុមការងារស្រាវជ្រាវនឹងបំពេញបន្ថែមទៅតាមអនុសាសន៍ ក្នុងអង្គប្រជុំ សូមថ្លែងអំណរគុណ USAID/WINROCK សម្រាប់ការគាំទ្រការវាយតម្លៃ ។ លោកជំទាវ បានមានប្រសាសន៍អរគុណ ក្រុមការងារវាយតម្លៃ ដែលខិតខំប្រឹងប្រែង ធ្វើការប្រមូលព័ត៌មានតាមគ្រប់រូបភាពក្នុងអំឡុងកូវីដ និងធ្វើការវិភាគយ៉ាងល្អិតល្អន់ ។ អរគុណក្រសួងស្ថាប័នពាក់ព័ន្ធ ដែល

បានចូលរួមផ្តល់ព័ត៌មានដោយឥតលាក់លៀមសម្រាប់ការឈានទៅដល់ការវាយតម្លៃបានត្រឹមត្រូវ ។ **លោកជំទាវ** មានប្រសាសន៍ថ្លែង អរគុណក្រុមការងារបកប្រែភាសា ធ្វើឲ្យមានការយល់គ្នាក្នុងថ្ងៃនេះ។ យើងនឹងមានកិច្ចការបន្តទៀតដើម្បីដាក់ចេញនូវសកម្មភាពគន្លឹះ ផែនការថវិកា ហើយសង្ឃឹមថាឯកឧត្តម លោកជំទាវ លោក លោកស្រី នឹងបន្តចូលរួម ក្នុងគោលបំណងរួមគឺលុបបំបាត់អំពើជួញដូរមនុស្ស ។

កិច្ចប្រជុំបាន បញ្ចប់នៅវេលាម៉ោង ដប់មួយ និង សែសិបប្រាំនាទី ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១

**អ្នកធ្វើរបាយការណ៍**

ស.ឯក រ៉េម សុភាក្របញ្ញា

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ៨រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណា សំខាន់

បានឃើញ

03/01/22

ជូ-ប៊ុនអេង